**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jan-2015, 15:08
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញា
# សុំឲ្យកោះហៅ ថេត សម្បត្តិ (2-TCW-885) ជាសាក្សីអានិភាព

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

## សំណើ

1. សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) ផ្តល់អាទិភាពចំពោះសក្ខីកម្មរបស់ ថេត សម្បត្តិ (2-TCW-885) ក្នុងសំណុំរឿង០០២/០២។ សម្ភារៈដែលស្ថិតនៅក្រោមការគ្រប់គ្រងជាសាធារណៈ បង្ហាញថាសាក្សីរូបនេះ ដែលសព្វថ្ងៃរស់នៅក្រៅប្រទេសកម្ពុជា និងដែលធ្លាប់បានបដិសេធម្តងហើយម្តងទៀត មិនព្រមសហការនៅក្នុងដំណើរការច្បាប់នៅ អ.វ.ត.ក អាចមានឆន្ទៈ ហើយអាចនឹងមកផ្តល់ភ័ស្តុតាងសំខាន់ៗនានា ដើម្បីទាំងដល់ការស្វែងរកការពិត។ ដោយផ្អែកលើខ្សែភាពយន្ត និងសៀវភៅរបស់គាត់ គាត់មានឯកសារជាច្រើនដែលទទួលស្គាល់ដោយ នួន ជា ដែលបង្ហាញអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ស្ថិតនៅក្នុងវិសាលភាពនៃសវនាការសំណុំរឿង០០២/០២។ ដូច្នេះ ទោះបីជាមានការបង្ហាញទំនាក់ទំនងផ្ទាល់ខ្លួន និងការអាណិតអាសូររបស់ ថេត សម្បត្តិ ចំពោះ នួន ជា សហព្រះរាជអាជ្ញាជឿជាក់ថា ភស្តុតាងនេះនឹងមានភវនីយភាពខ្ពស់ និងដាក់បន្ទុក។

2. នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ទាំងសហព្រះរាជអាជ្ញា និង នួន ជា បានលើកសំណើជូនអង្គជំនុំជម្រះសុំឲ្យ ថេត សម្បត្តិ ធ្វើជាសាក្សីក្នុងសំណុំរឿង០០២/០២[1]។ សហព្រះរាជអាជ្ញាស្វែងរកសក្ខីកម្មរបស់ ថេត សម្បត្តិ ជាបឋមទាក់ទងនឹងបទសម្ភាសន៍ជាច្រើនភាគដែលគាត់បានធ្វើជាមួយ នួន ជា ដែលបទសម្ភាសន៍ទាំងនោះ ត្រូវបានគេចងក្រងធ្វើជាភាពយន្តឯកសារ និងសៀវភៅ[2]។ ភាគីទាំងពីរក៏បានស្នើផងដែរឲ្យមានសក្ខីកម្មរបស់គាត់ នៅក្នុងសំណុំរឿង០០២/០១[3]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមិនអាចកោះហៅរូបគាត់បានក្នុងអំឡុងពេលដំណើរការនីតិវិធី

---

[1] **E305/6.1 ឧបសម្ព័ន្ធ ១**: បញ្ជីរួមនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង០០២/០២ តាមលំដាប់ដែលបានផ្តល់អនុសាសន៍នៃវគ្គសវនាការ និងការចូលបង្ហាញខ្លួនក្នុសវនាការ, ៩ ឧសភា ២០១៤ លេខ ៣(២)។ **E305/4.1 ឧបសម្ព័ន្ធ ក**: បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (គ្មានវិធានការការពារ), លេខ ២៧។

[2] **E3/4003R** សត្រូវរបស់ប្រជាជន **E3/4202** សៀវភៅនិពន្ធដោយ Gina Chon និង ថេត សម្បត្តិ មាន ចំណងជើងថា “លើសពីវាលពិឃាដ: មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះរបស់គាត់ម្នាក់” (Beyond the Killing Fields: a Khmer Rouge leader and one of his victims” (University of Pennsylvania Press, 2010)។

[3] **E9/4.3 ឧបសម្ព័ន្ធ ៣**: បញ្ជីសាក្សីរបស់ កសព, ២៨ មករា ២០១១ លេខ ២១៥។ **E9/4/4.4 ឧបសម្ព័ន្ធ ក**: បញ្ជីសាក្សី, ១៥ កុម្ភៈ ២០១១, លេខ ៤៥៦។

ដោយហេតុថា គាត់មិនបានឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់តុលាការ ដើម្បីទាក់ទងគាត់ ហើយគាត់បានស្នាក់នៅក្រៅប្រទេសកម្ពុជា (ស្នាក់នៅសហរដ្ឋអាមេរិក) ក្នុងអំឡុងពេលនោះ[4]។

3. ការរីកចម្រើនថ្មីៗ បង្ហាញថា ថេត សម្បត្តិ ពេលនេះ អាចមានបំណងចង់បង្ហាញខ្លួន និងផ្ដល់ភ័ស្តុតាងក្នុងសំណុំរឿង០០២/០២។ ការបោះពុម្ពផ្សាយថ្មីមួយនៃអត្ថបទរបស់ *វិទ្យុសម្លេងអាមេរិក* (**ឧបសម្ព័ន្ធ ១**) និយាយថា ថេត សម្បត្តិ "ចង់ផ្ដល់សក្ខីកម្មនៅសាលាក្ដីខ្មែរក្រហម" ដោយបានស្រង់សំដីផ្ទាល់របស់គាត់ដែលនិយាយត្រង់ថា "បើតុលាការយល់ព្រម និងបើតុលាការបើកចំហរសេរីភាពដល់ខ្ញុំ ខ្ញុំនឹងធ្វើ"[5]។ សេចក្ដីថ្លែងការណ៍ថ្មីៗទាំងនេះ គឺផ្ទុយគ្នាទៅនឹងការបដិសេធពីមុនៗ របស់ ថេត សម្បត្តិ មិនព្រមសហការជាមួយនឹងដំណើរការនីតិវិធីច្បាប់របស់ អ.វ.ត.ក ទាំងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០២[6] និងទាំងនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២/០១[7]។ សហព្រះរាជអាជ្ញាស្វាគមន៍ចំពោះការវិវឌ្ឍនេះ និងសុំឱ្យអង្គជំនុំជម្រះចាត់វិធានការឱ្យបានឆាប់រហ័ស ដើម្បីធានាឱ្យមានការទទួលយកភស្តុតាងរបស់គាត់នៅពេលដែលសាក្សីរូបនេះនៅតែមានឆន្ទៈផ្ដល់សក្ខីកម្ម។

4. ខណៈដែល ថេត សម្បត្តិ មាននៅក្នុងបញ្ជីឈ្មោះសាក្សីសម្រាប់សំណុំរឿង០០២/០២ រួចជាស្រេចទៅហើយនោះ សហព្រះរាជអាជ្ញាបានចាត់ទុកថា ភ័ស្តុតាងរបស់គាត់ គឺមានលក្ខណៈជាប់ទាក់ទងគ្នាខ្លាំងទៅនឹងដំណាក់កាលនៃសវនាការដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ និង

---

[4] **E294/1** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មី, ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣ ត្រង់កថាខណ្ឌ១៤។ **E292/1/2** អនុស្សរណៈរបស់អង្គភាព WESU ដែលមានចំណងជើងថា៖ "សាក្សីសក្ដានុពល - មិនអាចកំណត់ទីកន្លែងបានទេ", ៤ កក្កដា ២០១៣។

[5] **ឧបសម្ព័ន្ធ ១** *វិទ្យុសម្លេងអាមេរិក* ដាក់ចំណងជើងថា "អ្នកសារព័ត៌មានត្រូវបានស្នើឱ្យផ្ដល់សក្ខីកម្មនៅសាលាក្ដីខ្មែរក្រហម", ៦ មករា ២០១៥ ត្រង់ ERN ជាភាសាអង់គ្លេស 01054083-4 ។

[6] **D344** សំណើរបស់សហព្រះរាជអាជ្ញាសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងកិច្ចសម្ភាសន៍ នួន ជា និងខ្សែភាពយន្តឯកសាររឿង "សត្រូវរបស់ប្រជាជន", ៣ កុម្ភៈ ២០១០។ **D344/1.1** លិខិតរបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Marcel Lemonde ជូនលោក Robert Lemkin, ៣ កុម្ភៈ ២០១០។ **D344/1.2** អ៊ីម៉ែលរបស់លោក Rob Lemkin ជូនសហចៅក្រមស៊ើបអង្កេត Marcel Lemonde, ៩ កុម្ភៈ ២០១០ **D344/1** ដីកាសម្រេចស្ដីពីសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងខ្សែភាពយន្ត *សត្រូវរបស់ប្រជាជន* ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ ត្រង់កថាខណ្ឌ៨ ("សហចៅក្រមស៊ើបអង្កេតសំណែងការសោកស្ដាយយ៉ាងខ្លាំងថា ផលិតករខ្សែភាពយន្តបង្ហាញពីចេតនា ជាបន្តបន្ទាប់ មិនចង់សហការនៅពេលតុលាការស្វែងរកគាត់ និងទោះបីជាមានការធានាការសម្ងាត់ក៏ដោយ") ។

[7] **E294/1** សេចក្ដីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មី, ឱ្យចាប់ផ្ដើមការស៊ើបអង្កេត និងឱ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣ ត្រង់កថាខណ្ឌ១៤, ១៦ និងជើងសម្គាល់លេខយោង ៣១។ **E292/1/2** អនុស្សរណៈរបស់អង្គភាព WESU ដែលមានចំណងជើងថា៖ "សាក្សីសក្ដានុពល - មិនអាចកំណត់ទីកន្លែងបានទេ", ៤ កក្កដា ២០១៣។

សហឧក្រិដ្ឋកម្មរួម ដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទ "នៅចុងបញ្ចប់នៃសវនាការ"[8]។ ដោយផ្អែកលើការកំណត់ពេលសវនាការបច្ចុប្បន្ន ដំណាក់កាលនៃសវនាការនេះទំនងជានឹងមិនអាចធ្វើឡើងបានឡើយរហូតដល់ឆ្នាំ២០១៦។ ដោយសារតែសារៈសំខាន់នៃសក្ខីកម្មរបស់សាក្សីរូបនេះ និងកង្វះការសហប្រតិបត្តិការពីមុនរបស់គាត់ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់អាទិភាពដល់ការបង្ហាញខ្លួនរបស់គាត់ និងធ្វើតេស្តអំពីការផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់ដែលបានបង្ហាញនាពេលថ្មីៗនេះ ដោយការកោះហៅរូបគាត់ឱ្យមកផ្តល់សក្ខីកម្មនៅពេលឆាប់ៗបំផុតនេះ។

5. សហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថា មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យមានការបង្ហាញខ្លួន និងសក្ខីកម្មរបស់សាក្សីមួយចំនួន រួមមាន លោក ថេត សម្បត្តិ ឱ្យបានមុនអង្គជំនុំជម្រះតុលាការកំពូលដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១[9]។ សហព្រះរាជអាជ្ញាបានជំទាស់នឹងសំណើទាំងអស់ដោយមូលហេតុថា សំណើទាំងអស់នោះមិនឆ្លើយតបនឹងបទដ្ឋាននៃការបង្ហាញភស្តុតាងថ្មីចំពោះបណ្តឹងឧទ្ធរណ៍ និងការអូសបន្លាយនីតិវិធីដោយមិនសមស្រប។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ការផ្តល់ភាពមិនច្បាស់លាស់របស់មេធាវីការពារក្តីអំពីភស្តុតាងដែលសង្ឃឹមបានពីលោក ថេត សម្បត្តិ ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម ទួលពោធិ៍ជ្រៃ អាចមិនមែនជា "កត្តាសម្រេចទេ" នៅក្នុងសាលក្រមសំណុំរឿង០០២/០១ ហើយដូចនេះ មិនឆ្លើយតបចំពោះបទដ្ឋានដែលតម្រូវតាមវិធាន១០៨ (៧) នៃវិធានផ្ទៃក្នុង[10]។

6. ជាងនេះទៀត ដោយសារឋានៈរបស់គាត់ជាបុគ្គលសាធារណៈ ការដាក់ឯកសារទាក់ទិននឹង ថេត សម្បត្តិ ក្នុងបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ត្រូវបានចំណាត់ថ្នាក់ និងត្រូវបានផ្សព្វផ្សាយថាជាឯកសារសាធារណៈ។ (សម្រាប់ឯកសារយោង ឯកសារមួយច្បាប់របស់សហព្រះរាជអាជ្ញាដែលបានដាក់ទៅអង្គជំនុំជម្រះតុលាការកំពូលស្តីពីបញ្ហានេះដូចមាននៅក្នុង **ឧបសម្ព័ន្ធ ២**)។ តាមរយៈនេះ សហព្រះរាជអាជ្ញាបានស្នើថា ការដាក់ឯកសារនេះត្រូវបានចំណាត់ថ្នាក់ថាជា សាធារណៈ រួមជាមួយការកំណត់ឈ្មោះសាក្សី ប្រសើរជាងដាក់រហស្សនាមគាត់ថា(2-TCW-885)។

---

[8] **E315** សេចក្តីសម្រេចអំពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុសំណុំរឿង០០២/០២, ១២ កញ្ញា ២០១៤។

[9] **F2** សំណើសុំឱ្យពិចារណា និងទទួលភស្តុតាងបន្ថែមក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៤។

[10] **F2/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី១ និងទី២ របស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយក និងពិចារណាភស្តុតាងបន្ថែមក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤ ត្រង់កថាខណ្ឌ៦-១៦។

7. ចំពោះមូលហេតុទាំងនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

(ក) **ផ្តល់អាទិភាព** ចំពោះសវនាការស្តាប់ភ័ស្តុតាង ថេត សម្បត្តិ និង

(ខ) **កោះហៅ** ថេត សម្បត្តិ ឲ្យចូលមកបង្ហាញខ្លួនក្នុងឋានៈជាសាក្សីមួយរូបក្នុងសំណុំរឿង ០០២/០២ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញា | | |